ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ..១៤៧៣៧..អពដ

ថ្ងៃសុក្រ ៤ រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារកាលបរិច្ឆេទផុតកំណត់ប្រកាសបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនម្ចាស់អចលនទ្រព្យទាំងអស់ ដែលមានអចលនទ្រព្យស្ថិតក្នុងភូមិសាស្ត្រត្រូវបង់ពន្ធអចលនទ្រព្យ នៃរាជធានី-ខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា រហូតមកទល់ពេលនេះ មានម្ចាស់អចលនទ្រព្យជាច្រើនបានមកប្រកាសបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១៨ ហើយក៏នៅមានម្ចាស់អចលនទ្រព្យមួយចំនួនទៀត នៅមិនទាន់បានបំពេញកាតព្វកិច្ចប្រកាសបង់ពន្ធប្រភេទនេះនៅឡើយ។ អនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចប្រកាសបង់ពន្ធនេះ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ ផុតរយៈពេលនេះ អ្នកជាប់ពន្ធនឹងត្រូវទទួលរងទោសទណ្ឌស្របតាមច្បាប់ស្តីពីសារពើពន្ធជាធរមាន។

ដើម្បីផ្តល់លទ្ធភាពជូនដល់ម្ចាស់អចលនទ្រព្យ ដែលមានឆន្ទៈក្នុងការបំពេញកាតព្វកិច្ចប្រកាសបង់ពន្ធនេះ ប៉ុន្តែមិនទាន់បានមកប្រកាសបង់ពន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសម្រេចអនុញ្ញាតឱ្យ អគ្គនាយកដ្ឋានពន្ធដារពន្យារកាលបរិច្ឆេទផុតកំណត់ប្រកាសបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១៨ រហូតដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ដោយរួចផុតពីពិន័យទោសទណ្ឌដោយសារការប្រកាសបង់ពន្ធយឺតយ៉ាវ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា ក្នុងអំឡុងពេលនៃការពន្យារការបង់ពន្ធប្រភេទនេះ ម្ចាស់អចលនទ្រព្យទាំងអស់នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលា និងបានគ្រប់ៗគ្នា តាមការកំណត់ជាក់ជាមិនខាន។

Collection by VCAT Professional Consultant

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700 Email: gdt@tax.gov.kh Website: www.tax.gov.kh